**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

# សេចក្តីជូនដំណឹងដល់បេក្ខជន

ដើម្បីរក្សាសណ្តាប់ធ្នាប់របៀបរៀបរយ និងវិន័យនៃការប្រឡង គណៈកម្មការប្រឡងសូមជូនដំណឹងថា បេក្ខជនទាំងឡាយត្រូវគោរពតាមបទបញ្ញត្តិ ដូចខាងក្រោមឲ្យបានល្អះ

១. ត្រូវយកជាប់ជាមួយខ្លួននូវសលាប័ត្រឯកត្តជនមានបិទរូបថត និងមានហត្ថលេខាត្រឹមត្រូវ ព្រមទាំងប័ណ្ណទទួលពាក្យសុំចុះឈ្មោះប្រឡង។

២. មិនត្រូវយកឯកសារ សៀវភៅ សំណៅ ក្រដាសព្រាង ប៊ិចខ្មៅដៃ ជ័រលុប ទឹកលុប កាតាប សំពៀត ថង់កញ្ចប់គ្រប់ប្រភេទចូលក្នុងបន្ទប់ប្រឡងជាដាច់ខាត។ បើមានយកជាប់មកជាមួយ ត្រូវផ្ញើទៅអ្នកយាម ឬ អ្នកត្រួតពិនិត្យនៅតាមច្រកទ្វារសាលា ឬ ច្រកចូលអាគារ។

៣. ហាមយកអាវុធ ឬគ្រឿងផ្ទុះគ្រប់ប្រភេទ ទូរស័ព្ទ និងឧបករណ៍អេឡិចត្រូនិចគ្រប់ប្រភេទចូលក្នុងមណ្ឌលប្រឡងជាដាច់ខាត។

៤. បេក្ខជនត្រូវបង្កលក្ខណៈងាយស្រួលឲ្យអ្នកមានសមត្ថកិច្ចត្រួតពិនិត្យ តាមការណែនាំរបស់គណៈមេប្រយោគ ហើយត្រូវគោរពតាមសំណូមពររបស់អ្នកត្រួតពិនិត្យក្នុងការដកហូតទុកនូវសម្ភារៈ ឬ របស់អ្វីដែលគ្មានការអនុញ្ញាតឲ្យចូលក្នុងបន្ទប់ប្រឡង។

៥. ត្រូវគោរពបទវិន័យនៃការប្រឡងតាមការណែនាំរបស់គណៈមេប្រយោគ ដាច់ខាតមិនធ្វើឲ្យខូចរបៀបរៀបរយ និង សណ្តាប់ធ្នាប់នៃការប្រឡងឡើយដូចជា អង្គុយតាមលេខតុដែលអនុរក្សបង្ហាញ សរសេរឈ្មោះ និងលេខតុនៅលើក្បាលសន្លឹកប្រឡងដែលអនុរក្សចែកឲ្យតាមការណែនាំ និងប្រគល់សន្លឹកកិច្ចការប្រឡងដល់អនុរក្សវិញ ទោះបីជាក្រដាសប្រឡងគ្មានសរសេរចម្លើយ ឬ ដំណោះស្រាយអ្វីក៏ដោយ។ បេក្ខជនដែលមិនប្រគល់សន្លឹកកិច្ចការប្រឡងដល់អនុរក្សនឹងត្រូវបានពិន្ទុសូន្យ។

៦. ហាមលួចចម្លង មើលគ្នា សួរគ្នា ឬសរសេរហើយអានខ្លាំងៗឮដល់បេក្ខជនដទៃទៀតក្នុងពេលកំពុងធ្វើវិញ្ញាសា។

រាជធានីភ្នំពេញ ថ្ងៃទី១២ខែកក្កដា ឆ្នាំ២០១៦

**ប្រធានគណៈកម្មការប្រឡង**

**យុន្ន ត្វាថង**

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320